អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ២០១០

# សេចក្តីប្រកាសព័ត៌មាន

## លោក Philippe Gréciano
## ត្រូវបានតែងតាំងជាសហមេធាវីការពារក្តីអោយលោក ខៀវ សំផន

លោក ភីលីព គ្រេស្យាណូ (Philippe Gréciano) ត្រូវបានតែងតាំងនៅថ្ងៃនេះ អោយធ្វើជាសហមេធាវីនូវជាតិការពារក្តីលោក ខៀវ សំផន។គាត់នឹងធ្វើការជាមួយលោកមេធាវី Jacques Verges និងលោកមេធាវី ស ស្វ៉ាន នៅក្នុងក្រុមមេធាវីការពារក្តីអោយ លោក ខៀវ សំផន។

លោក ភីលីព គ្រេស្យាណូ គឺជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យមួយក្នុងប្រទេសបារាំង ហើយគាត់ជាសមាជិកនៃគណៈមេធាវីរបស់ទីក្រុងប៉ារីសផងដែរ។ គាត់មានបទពិសោធន៍ជាង១៥ឆ្នាំ ក្នុងការងាររបស់គាត់ ហើយគាត់ធ្លាប់បានធ្វើការពាក់ព័ន្ធនឹងរឿងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ៧ ករណី នៅឯតុលាការក្នុងប្រទេស រ្វ៉ាន់ដា តុលាការឧក្រិដ្ឋកម្មនៅក្នុងប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់ ក៏ដូចជានៅចំពោះមុខតុលាការអន្តរជាតិពិសេសសំរាប់ប្រទេស រ្វ៉ាន ដាផងដែរ។